ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ២៧០ ក.ប/ស.ជ.៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពង្រឹងការយកចិត្តទុកដាក់ចំពោះកម្មសិក្សាការីខ្មែរ ដែលកំពុងធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនដែលកំពុងដំណើរការក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាការីខ្មែរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនឱ្យបានជ្រាបថា នាពេលថ្មីៗនេះមានកម្មសិក្សាការីខ្មែរមួយចំនួនបានចាញ់បោកមេខ្យល់អូសទាញឱ្យក្លាយជាកម្មសិក្សាការីខុសច្បាប់ ក្រោមរូបភាពនៃការផ្តល់កន្លែងធ្វើការថ្មីដែលស្របច្បាប់ ទទួលបានប្រាក់បៀវត្សច្រើនជាងមុន និងទទួលបានសិទ្ធិស្នាក់នៅស្របច្បាប់នៅប្រទេសជប៉ុន។ ការរត់គេចខ្លួននេះនឹងបង្កផលលំបាកដល់កម្មសិក្សាការីផ្ទាល់ឱ្យក្លាយជាកម្មសិក្សាការីខុសច្បាប់ ខាតបង់ប្រាក់ឱ្យមេខ្យល់ ប្រឈមនឹងការចាប់ខ្លួន បាត់បង់ឱកាសរកប្រាក់ រីឯក្រុមគ្រួសារកម្មសិក្សាការីក៏អាចរងពាក្យបណ្តឹងដោយសារការមិនបានអនុវត្តតាមកិច្ចសន្យា និងលទ្ធផលអាក្រក់បំផុតអាចធ្វើឱ្យកម្ពុជាបាត់បង់ទីផ្សារការងារដ៏ល្អនៅប្រទេសជប៉ុន។

ជាថ្មីម្តងទៀត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមក្រើនរំលឹកដល់បងប្អូនកម្មសិក្សាការីខ្មែរថាអ្នកទាំងអស់គ្នាមិនអាចផ្លាស់ប្តូរកន្លែងធ្វើការរបស់ខ្លួនបានជាដាច់ខាត។ ក្នុងករណីដែលមានបញ្ហាអ្វីមួយកើតឡើងនៅកន្លែងធ្វើការ សូមកម្មសិក្សាការីស្វែងរកការអន្តរាគមន៍ពីសមាគមគ្រប់គ្រង ឬស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន តាមរយៈទូរស័ព្ទលេខ 080 4689 9374 ឬតាមបណ្តាញសង្គមហ្វេសប៊ុក Royal Embassy of Cambodia in Japan ។

ដោយឡែក ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវបង្កើនការយកចិត្តទុកដាក់លើការគ្រប់គ្រង ផ្តល់ប្រឹក្សា និងពង្រឹងទំនាក់ទំនងជាមួយកម្មសិក្សាការីរបស់ខ្លួនឱ្យបានជិតស្និទ្ធ។ នៅពេលមានករណីកម្មសិក្សាការីរត់គេចខ្លួន ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវរួសរាន់រាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច(ប៉ូលីស) និងស្ថាប័នពាក់ព័ន្ធនៅប្រទេសជប៉ុន ជាពិសេសស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន បន្ទាប់មកជូនដំណឹងដល់ក្រុមគ្រួសារកម្មសិក្សាការីដោយមានអាជ្ញាធរមូលដ្ឋានដឹងឮ។ បន្ទាប់មក ទីភ្នាក់ងារជ្រើសរើសឯកជនផ្ញើរបាយការណ៍ពាក់ព័ន្ធទាំងនោះ មកនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសង្ឃឹមយ៉ាងមុតមាំថា ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការីទាំងអស់ចូលរួមសហការ និងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយទំនួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន៖
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (ដើម្បីជូនជ្រាប)
- ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា
- សមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (ដើម្បីជ្រាប និងអនុវត្ត)
- ឯកសារ កាលប្បវត្តិ